# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ក្នុងកំឡុងត្រីមាសទី១ ២០០៦ ផសស ពិត នៅ US កើនខ្ពស់ជាងកាលពីមួយឆ្នាំមុន ៥,៦% ធៀបនឹងកំណើន ១,១% នៅត្រីមាសទី៤ ២០០៥ ។ សន្ទុះកំណើន ផសស ពិត នៅត្រីមាសទី១នេះ សំខាន់គឺដោយសារកំណើននៃចំណាយប្រើប្រាស់ផ្ទាល់ខ្លួន វិនិយោគក្នុងស្រុករបស់ឯកជន និងចំណាយរដ្ឋាភិបាលសហព័ន្ធ ។

នៅត្រីមាសទី១ ២០០៦ ផសស ពិត នៅតំបន់អឺរ៉ូ កើនឡើងតាមអត្រាប្រចាំឆ្នាំ ២,០% រីកើន ០,៦% ធៀបនឹងត្រីមាសមុន ។ ផសស ពិត នៅជប៉ុន កើនតាមអត្រាប្រចាំឆ្នាំ ៣,០% រីកើន ០,៥% ធៀបនឹងត្រីមាសមុន ។

ចិន នៅតែមានកំណើនសេដ្ឋកិច្ចកើរតខ្ពស់ នៅត្រីមាសទី១ ២០០៦ ដោយមានកំណើន ផសស ពិត ១០,៩% រី ១,០% ខ្ពស់ជាងនៅត្រីមាសមុន ។ វិស័យទី២ (ឧស្សាហកម្ម) មានកំណើនខ្ពស់បំផុត គឺ ១៣,២% រីឯ វិស័យទី១ និងទី៣ មានអត្រាកំណើនទាបជាងត្រឹម ៩,៤% និង ៥,១% ។ ផសស ពិត នៅកូរ៉េខាងត្បូង នៅត្រីមាសទី១ ២០០៦ កើនតាមអត្រាប្រចាំឆ្នាំ ៦,១% ធៀបនឹងកំណើន ៥,២% នៅត្រីមាសទី៤ ២០០៥ ។ ផសស ពិត នៅហុងកុង កើនតាមអត្រាប្រចាំឆ្នាំ ៨,២% ហើយនៅតៃវ៉ាន់ វាកើន ៤,៩% ។

នៅត្រីមាសទី១ ២០០៦ សេដ្ឋកិច្ចម៉ាឡេស៊ី មានអត្រាកំណើន ៥,៣% ធៀបនឹងកំណើន ៥,២% នៅត្រីមាសទី៤ ២០០៥ ។ នៅខាងផលិតកម្មវិញ ផ្នែកកម្មន្តសាល មានកំណើនយ៉ាងខ្ពស់ដល់ ៨% ។ រីឯនៅខាងផ្នែកចំណាយ ចំណាយឯកជនបាននាំមុខគេដោយកើន ៧,៥% ។ សេដ្ឋកិច្ចសិង្ហបុរី នៅត្រីមាសទី១ ២០០៦ បន្តកើនឡើងយ៉ាងខ្លាំងដល់ទៅ ១០,៧% ។ ខាងកម្មន្តសាល កើនបាន ២០,២% រីឯវិស័យសេវាកម្ម កើនបាន ៧% ។ ផសស ពិត នៅថៃ នៅត្រីមាសទី១ ២០០៦ កើនបាន ៦,០% ធៀបនឹងកំណើន ៤,៧% នៅត្រីមាសមុន ។ វិស័យកសិកម្ម មានកំណើនយ៉ាងខ្ពស់ដល់ ៧,១% ធៀបនឹងការធ្លាក់ចុះ ០,២% នៅត្រីមាសទី៤ ២០០៥ ។ វិស័យមិនមែនកសិកម្មកើនបាន ៥,៩% ធៀបនឹងកំណើន ៥,៣% នៅត្រីមាសមុន ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី១ ២០០៦ ថ្លៃទំនិញប្រើប្រាស់នៅ US កើនតាមអត្រាប្រចាំឆ្នាំ ៣,៧% ដែលបណ្តាលជាសំខាន់មកពីកំណើនថ្លៃថាមពល និងម្ហូបអាហារ ។ នៅតំបន់អឺរ៉ូ អតិផរណាថយចុះមកត្រឹម ២,៣% ធៀបនឹង កើរត ២,៤% នៅត្រីមាសទី៤ ២០០៥ ដែលជាសំខាន់បណ្តាលមកពីការថយចុះអតិផរណាថ្លៃថាមពល និងការថយចុះអត្រាកំណើនប្រចាំឆ្នាំនៃថ្លៃម្ហូបមិនកែច្នៃ ។ ក្នុងកំឡុងពេលដដែល បំរែបំរួលពីមួយឆ្នាំទៅមួយឆ្នាំនៃថ្លៃទំនិញប្រើប្រាស់នៅជប៉ុន មានកំណើន ០,៤% ធៀបនឹងការធ្លាក់ចុះ ០,៥% នៅត្រីមាសមុន ហើយផលិតផលឥន្ធនៈជាមូលហេតុចំបងនាំឱ្យមានកំណើននេះ ។ អតិផរណានៅថេរគួរសមក្នុងប្រទេសផ្សេងទៀតនៅអាស៊ី ។ ឧទាហរណ៍ នៅកូរ៉េខាងត្បូង និងសិង្ហបុរី អតិផរណាមានកើរត ២,៤% និង ១,១% នៅត្រីមាសទី១ ឆ្នាំ២០០៦ ។

នៅត្រីមាសទី១ ២០០៦ ក្នុងទីផ្សារប្តូរប្រាក់ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ បន្ទាប់ពីការឡើងថ្លៃនៅត្រីមាសទី៤ ២០០៥ ។ ទល់នឹងប្រាក់យ៉េនជប៉ុន និងប្រាក់អឺរ៉ូ ដុល្លារUS ប្តូរបាន ១១៤,៥យ៉េន/ដុល្លារ និង ០,៨០អឺរ៉ូ/ដុល្លារ ដោយធ្លាក់ថ្លៃពី ១១៧,២យ៉េន/ដុល្លារ និង ០,៨៤អឺរ៉ូ/ដុល្លារ នៅត្រីមាសទី៤ ២០០៥ ។ ទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូង និងប្រាក់យ៉ួនចិន វាប្តូរបាន ៩៧៦វ៉ុន/ដុល្លារ និង៨,០៥យ៉ួន/ដុល្លារ ដោយធ្លាក់ថ្លៃពី ១០៣៦វ៉ុន/ដុល្លារ និង ៨,០៨យ៉ួន/ដុល្លារ នៅត្រីមាសមុន ។ ការធ្លាក់ថ្លៃប្រាក់ដុល្លារUS ប្រហែលទទួលឥទ្ធិពលពីការរំពឹងទុកនៅទីផ្សារ ស្តីពីគោលនយោបាយរូបិយវត្ថុនៅ US និងឱនភាពគណនីចរន្តរបស់ US ដែលឡើងខ្ពស់បំផុតនៅឆ្នាំ២០០៥ ។

## ថ្លៃផលិតផលនៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ២០០៦ ថ្លៃអង្ករ ពោត ប្រេងឆា និងប្រេងឆៅ កើនឡើង រីឯ ថ្លៃសាំង ធ្លាក់ចុះ ។ ថ្លៃអង្ករ Thai 100%B លេខ២ នៅទីផ្សារបាងកក គឺ ២៧៥,១២ដុល្លារ/តោន ធៀបនឹង ២៥៩,៤០ដុល្លារ/តោន នៅត្រីមាសទី៤ ២០០៥ ។ ប្រេងឆាលក់បាន ៣៩៥,៧៧ដុល្លារ/តោន នៅត្រីមាសទី១

**តារាង១. កំនើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | - | - | - | - | - | 13.4 |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 6.4 | 5.5 | 5.3 | 4.9 | 4.6 | 5.6 |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 5.7 | 4.4 | 5.3 | 5.2 | 5.3 | 5.2 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 2.5 | 5.4 | 7 | 7.7 | 10.7 | 5.7 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 3.3 | 4.6 | 5.3 | 4.7 | 6.0 | 4.5 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | - | - | - | - | - | 8.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.5 | 9.5 | 9.4 | 9.9 | 10.9 | 9.6 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 2.7 | 7.3 | 8.2 | 7.6 | 8.2 | 6.5 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 6 | 3.3 | 4.4 | 5.2 | 6.1 | 4.7 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 2.7 | - | - | 6.0 | 4.9 | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.3 | 1.2 | 1.5 | 1.8 | 2.0 | 1.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 1.3 | 1.4 | 2.9 | 4.5 | 3.0 | 2.5 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 3.5 | 3.3 | 4.1 | 1.1 | 5.6 | 3.0 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

២០០៦ រឺ កើន ១% ធៀបនឹងត្រីមាសមុន ។ ពោតលក់បាន ៩៥,៣៣ដុល្លារ/តោន រឺ កើន ៥% ធៀបនឹងត្រីមាសទី៤ ២០០៥ ។ ថ្លៃសណ្តែកសៀង នៅថេរ ដោយលក់បានដូចគ្នានឹងត្រីមាសមុន គឺ ២១០,៩៦ដុល្លារ/តោន ។ ថ្លៃប្រេងឆៅ នៅត្រីមាសទី១ ២០០៦ កើនឡើង ៩% រឺង ថ្លៃសាំងធ្លាក់ចុះ ៣% ធៀបនឹងត្រីមាសទី៤ ២០០៥ ។ នៅត្រីមាសទី១ ប្រេងឆៅលក់បាន ៥៧,៨៩ដុល្លារ/ធុង រឺងសាំងលក់បាន ៤១,១៨សេន/លីត្រ ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភីម រុនស៊ីណារិទ្ធិ*

**តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 5.6 | 6.4 | 4.6 | 6.6 | 5.9 | 5.8 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 10.7 | 10.8 | 12 | 17.3 | - | 10.5 |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 2.5 | 3.0 | 3.4 | 3.4 | 3.9 | 3.1 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.4 | 0.1 | 0.5 | 1.1 | 1.1 | 0.5 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 2.8 | 3.7 | 5.6 | 6.0 | 5.7 | 4.5 |
| វៀតណាម | -0.4 | 3.8 | 3.2 | 8.3 | 9.0 | 8.0 | 7.5 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 2.8 | 1.7 | 1.3 | 1.4 | 1.2 | 1.8 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 0.4 | 0.8 | 1.4 | 1.8 | 2.0 | 1.1 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 3.2 | 3.0 | 2.4 | 2.5 | 2.4 | 2.8 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 1.6 | 2.1 | - | 2.4 | - | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.1 | 2.1 | 2.3 | 2.4 | 2.3 | 2.2 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.2 | -0.1 | -0.3 | -0.5 | 0.4 | -0.3 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.0 | 2.9 | 3.8 | 3.7 | 3.7 | 3.4 |

*Source: International Monetary Fund, Economist and National Institute of Statistics*

**តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,916.3 | 3,912.1 | 3,973 | 4,016.3 | 4,027.0 | 4,054.3 | 4134.3 | 4154.3 | - | 4,092.5 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9,311 | 8,577 | 8,938 | 9,274 | 9,550 | 9,994 | 9,999 | - | 9,705 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.77 | 3.78 | 3.73 | 3.79 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.63 | 1.66 | 1.68 | 1.69 | 1.63 | 1.66 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 38.6 | 40.1 | 41.3 | 41.02 | 39.3 | 40.2 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,809 | 15,842 | 15,878 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.14 | 8.08 | 8.05 | 8.19 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.80 | 7.79 | 7.77 | 7.75 | 7.76 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,291 | 1,251 | 1,192 | 1,145 | 1,022 | 1,008 | 1,029 | 1,036 | 976 | 1,024 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 31.5 | 31.4 | 32.3 | 33.4 | 32.3 | 32.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.76 | 0.79 | 0.81 | 0.84 | 0.80 | 0.80 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 104.7 | 107.4 | 111.2 | 117.2 | 114.5 | 110.2 |

*Source: International Monetary Fund and Economist and National Bank of Cambodia*

**តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០០-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 87.98 | 87.53 | 90.61 | 90.64 | 95.37 | 89.19 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 374.86 | 382.48 | 376.41 | 391.52 | 395.75 | 381.32 |
| កៅស៊ូ – ម៉ាឡេស៊ី ($/តោន) | 602.0 | 768.3 | 1050 | 1252.2 | - | - | - | - | - | - |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 268.11 | 268.20 | 255.77 | 259.40 | 275.12 | 262.88 |
| សណ្តែកសៀង (US No. 1) – US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 208.52 | 263.66 | 214.37 | 210.42 | 210.96 | 224.25 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 42.6 | 47.7 | 57.27 | 52.99 | 57.89 | 50.14 |
| សាំង – US Gulf coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 34.4 | 39.7 | 52.37 | 42.29 | 41.18 | 42.19 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*
*Note: All prices have been converted from US$/ton to US$/tonne, which 1 ton = 0.907 tonne.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សេចក្តីផ្តើម

ធនាគារពិភពលោក បានធ្វើចំណាត់ថ្នាក់កម្ពុជាជា ប្រទេសមានចំណូលទាប នៅតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក យោងតាមលទ្ធផលសេដ្ឋកិច្ចក្នុងពេលថ្មីៗ ។ នៅកំឡុងឆ្នាំ២០០១-២០០៥ ផសស ពិត មានអត្រាកំណើនជាមធ្យម ១១,២% និងអត្រាកំណើនគិតក្នុងមនុស្សម្នាក់ ៩,៣% ។ នេះជាលទ្ធផលសេដ្ឋកិច្ចដ៏ល្អមួយ ធៀបនឹងកំណើនពិតជាមធ្យម ៣,០% នៅកំឡុងឆ្នាំ ១៩៩៧-២០០១ ។

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ២០០៦ វិនិយោគឯកជន និងទេសចរណ៍ មានចំណែកយ៉ាងធំនៅក្នុងសេដ្ឋកិច្ចកម្ពុជា រីឯវិស័យសាងសង់ និងពាណិជ្ជកម្មក្រៅប្រទេស មានការធ្លាក់ចុះ បើធៀបនឹងត្រីមាសមុន ។

វិនិយោគឯកជនសរុបក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម បានរីកចំរើនលូតលាស់នៅក្នុងត្រីមាសនេះ ដោយសារការពង្រីកគំរោង បន្ទាប់ពីមានកំណើន ផសស ក៏រិតខ្ពស់នៅឆ្នាំ២០០៥ (អត្រាចារិក ១៩,៩% និងអត្រាពិត ១៣,៤%) ដែលបានទាក់ទាញវិនិយោគិន ប៉ុន្តែកំណើននេះមិនរំពឹងថា នឹងបន្តបានយូរទេ ។ ការអនុមតិវិនិយោគឯកជន គិតជាទ្រព្យសកម្មជាប់លាប់ កើនដល់ ៩១% ដល់ ២២៧,៣លានដុល្លារ នៅត្រីមាសទី១ ។ បើតាមទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា (CDC) ការអនុមតិវិនិយោគខាងកសិកម្ម គិតជាទ្រព្យសកម្មជាប់លាប់បានចុះបញ្ជី មាន ១២៦,៥លានដុល្លារ នៅត្រីមាសទី១ រីកើនជិតដល់ ១៣ដង ធៀបនឹងត្រីមាសមុន ។ វិនិយោគក្នុងវិស័យសេវាកម្ម កើនទ្វេមួយជាពីរ ដល់ ៦០,៧លានដុល្លារ រីឯវិនិយោគខាងឧស្សាហកម្ម បានធ្លាក់ចុះអស់ ៥១% ពី ៨២,០លានដុលារ មកដល់ត្រឹម ៤០,១លានដុល្លារ ។ ម្យ៉ាងវិញទៀត នៅត្រីមាសទី១ ២០០៦ ការអនុមតិគំរោងវិនិយោគឯកជន សរុបគិតជាទ្រព្យសកម្មជាប់លាប់ រួមទាំងគំរោងពង្រីកបន្ថែមផង បានធ្លាក់ចុះមកដល់ ៥២% ពីកំរិត ៤៧៥,៣លានដុល្លារ នៅត្រីមាសដូចគ្នា ឆ្នាំ២០០៥ (នៅឆ្នាំនោះ កំណើនកើតចេញពីវិនិយោគខាងឧស្សាហកម្ម) ។ ប៉ុន្តែកំណើនវិនិយោគឯកជន បានជួយដល់សេដ្ឋកិច្ចកម្ពុជា ក្នុងត្រីមាសនេះ ។

ជាច្រើនឆ្នាំកន្លងទៅ ទេសចរណ៍កើនឡើងជាប់ជានិច្ច ។ កម្ពុជាទាក់ទាញភ្ញៀវទេសចរបរទេសបានកាន់តែច្រើន ដោយសារសៀមរាប (អង្គរ) កាន់តែមានគេស្គាល់ច្រើន ស្ថានភាពសន្តិសុខក៏មានស្ថិរភាព ហើយហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ក៏ប្រសើរជាងមុន ។ នៅត្រីមាសទី១ ២០០៦ ភ្ញៀវមកដល់កម្ពុជា មានសរុប ៤៥៧.៣០០នាក់ រីកើន ៩,៩% ធៀបនឹងត្រីមាសមុន និងកើន ២០% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ។ ក្នុងនោះ ៨៨% (៤០០.៤១៧នាក់) មកសំរាកលំហែវិសមកាល ហើយ ៥,៦% (២៥.៣៨៦នាក់) មកធ្វើការងារផ្លូវការរដ្ឋ និងកិច្ចការជំនួញ ។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលភ្ញៀវបរទេស ១០៣.២០៣នាក់ នៅត្រីមាសទី១ (ធៀបនឹង ១១៧.៥១៦នាក់ នៅត្រីមាសមុន) រីឯអាកាសយានដ្ឋានអន្តរជាតិសៀមរាប ទទួលភ្ញៀវកើនឡើង ២៩% ដល់ ១៧២.១៨៨នាក់ ធៀបនឹង ១៣៣.៩៨៤នាក់ នៅត្រីមាសទី៤ ២០០៥ ។ ភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក កើន ១១% ដល់ ១៨១.៩០០នាក់ ក្នុងនេះ ៩៣% មកតាមផ្លូវគោក (ធៀបនឹង ៩៥% នៅ ត្រីមាសមុន) ។ កូរ៉េ ជាប្រភពភ្ញៀវច្រើនជាងគេបង្អស់ គឺ ១០០.១៨៧នាក់ រឺ ២២% នៃភ្ញៀវចូលសរុប បន្ទាប់មកគឺ ជប៉ុន (៤៣.៦១៧នាក់) និងសហរដ្ឋអាមេរិក (៣៣.៤០៤នាក់) ។

ជនចំណាកស្រុកចូល គិតទាំងអ្នកចូលមកពីប្រទេសក្រៅផង បានបង្កើនចំនួនប្រជាជននៅភ្នំពេញ ។ កំនើនប្រជាជន គួបនឹងកំនើនសេដ្ឋកិច្ចកំរិតខ្ពស់ នាំឱ្យមានកំណើនសកម្មភាពសាងសង់នៅភ្នំពេញ ក្នុងជាច្រើនឆ្នាំកន្លងមកនេះ ។ ប៉ុន្តែ នៅត្រីមាសទី១ វិស័យសាងសង់នៅភ្នំពេញបានបន្តនិន្នាការធ្លាក់ចុះ ដែលបានចាប់ផ្តើមតាំងពីត្រីមាសទី២ ២០០៥ ។ គេហាក់ពិនិត្យឃើញថា គំរោងសាងសង់ដែលអនុម័តពីមុន បានអនុវត្តរួចហើយ ប៉ុន្តែសន្ទុះកំនើននោះ មិនអាចរក្សាបានជាបន្តមកទៀតទេ ។ យោងតាមទិន្នន័យពីនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រក្រុងភ្នំពេញ ការអនុមតិគំរោងសាងសង់មាន ៦៧,៣លានដុល្លារ រឺ ធ្លាក់ចុះ ៦,៣% ធៀបនឹងកំរិត ៧១,៨លានដុល្លារ នៅត្រីមាសមុន និងធ្លាក់ចុះយ៉ាងខ្លាំងធៀបនឹងកំរិត ១០៦,១លានដុល្លារ នៅត្រីមាសដូចគ្នា ឆ្នាំ២០០៥ ។ ការអនុមតិសំណង់ផ្ទះល្វែងគឺ ៣៩,៩លានដុល្លារ រឺ ១២% ទាបជាងនៅត្រីមាសមុន ហើយការអនុមតិសំណង់ផ្សេងៗ ធ្លាក់ចុះ ១៨% មកត្រឹម ១៧,៤លានដុល្លារ ប៉ុន្តែការអនុមតិសំណង់ភូមិគ្រឹះ និងផ្ទះកើនជិតទ្វេដងពី ៥,៤លានដុល្លារ ដល់ ១០,១លានដុល្លារ ។ នៅឆ្នាំ២០០៥ សកម្មភាពសាងសង់នៅភ្នំពេញ កើនឡើង ៣៦% ដល់ ៣៥៨,៨លានដុល្លារ ធៀបនឹង ២៦៣,៤លានដុល្លារ នៅឆ្នាំ២០០៤ ។ កំណើននេះនាំមុខគេដោយសំណង់ផ្ទះល្វែង ដែលមានតំលៃដល់ ២០៤,២លានដុល្លារ និងដែលនៅតែនាំមុខគេក្នុងកំឡុងពេលនេះទៀត ។

ក្នុងកំឡុងពេលនេះដែរ ការអនុមតិគំរោងសាងសង់នៅភ្នំពេញធ្លាក់ចុះ រីឯវិនិយោគឯកជន និងវិស័យទេសចរណ៍ កើនឡើង ។ ម្យ៉ាងទៀត ឱនភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា បានកើនដល់ ៨៧,៥លានដុល្លារ ធៀបនឹង ៤៦,៣លានដុល្លារ នៅត្រីមាសមុន បន្ទាប់ពីមាន អតិរេក ៩៧,៧លានដុល្លារ នៅត្រីមាសទី៣ ឆ្នាំ២០០៥ ។ នៅត្រីមាសទី១ ២០០៦ ទោះបីការនាំចូលបានធ្លាក់ចុះ ប៉ុន្តែការនាំចេញសរុប ក៏ធ្លាក់ចុះអស់ ៦,៥% ដែរ មកត្រឹម ៦០៣,២លានដុល្លារ ដែលផ្ទុយពីកំណើន ៣០% នៅត្រីមាសដូចគ្នាឆ្នាំមុន ។ ក្នុងចំណោមផលិតផលនាំចេញចំបងៗ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះអស់ ៥,៤% ពី ៦០១,០លានដុល្លារ មកត្រឹម ៥៦៨,៥លានដុល្លារ ក្នុងនេះ ការនាំចេញសំលៀកបំពាក់ទៅសហរដ្ឋអាមេរិក និងអឺរ៉ុបបានធ្លាក់ចុះអស់ ១,៤% និង ២៤% ។ ការនាំចេញកៅស៊ូ ធ្លាក់ចុះ ៤២% មកត្រឹម ៧,៨លានដុល្លារ ការនាំចេញត្រីចុះអស់ ៧១% មកត្រឹម ១,៩លានដុល្លារ ប៉ុន្តែ ការនាំចេញឈើ និងផលិតផលផ្សេងទៀត កើនបាន ៥,០% និង ៤,៦% ។ កំនើនការនាំចេញ អាចផ្តល់ចំនូលបន្ថែមដល់កម្ពុជា ប៉ុន្តែនៅត្រីមាសទី១ ការនាំចេញតែងតែធ្លាក់ចុះ ដោយសារកត្តារដូវកាល ពីព្រោះសំលៀកបំពាក់មួយភាគធំលក់ទៅបណ្តាប្រទេសខាងជើង ដែលមានរដូវទិញដូរចំបងនៅត្រីមាសទី៣ និង ទី៤ ។ តាមធម្មតាការនាំចេញសំលៀកបំពាក់ តែងជាកត្តាកំនត់ចំពោះលទ្ធផលការនាំចេញ ។ ការនាំចេញផលិតផលកសិកម្ម ក៏ពាក់ព័ន្ធនឹងកត្តារដូវកាលដែរ ហើយមូលហេតុមួយនៃការធ្លាក់ចុះ គឺការបង្វែរផលិតផលទៅតាមច្រក "មិនផ្លូវការ" ពោលគឺការលក់ដូរដោយផ្ទាល់នូវផលិតផលកសិកម្មក្នុងតំបន់ព្រំដែន ទៅឱ្យឈ្មួញនៅប្រទេសជិតខាង ដែលជួនកាលប្រជាជនអាចលក់បានថ្លៃជាងតាមវិធីនេះ ។

នៅត្រីមាសទី១ ២០០៦ ការនាំចូលសរុបដែលរាយការណ៍ឡើងដោយទីចាត់ការគយនិងរដ្ឋាករ ស្ទើរគ្មានការប្រែប្រួលដោយមានតំលៃសរុប

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

៦៩០,៧លានដុល្លារ ធៀបនឹង ៦៩១,១លានដុល្លារនៅត្រីមាសទី៤ ២០០៥ ។ ការនាំចូលម្ហូបអាហារ និងក្រណាត់ ធ្លាក់ចុះអស់ ១,០% និង ៩,០% មកត្រឹម ១០,០លានដុល្លារ និង ២,០លានដុល្លារ ។ ការនាំចូលសាំង និងម៉ាស៊ូត កើន ១,៩% និង ៥៤% ដល់ ១០,៩លានដុល្លារ និង ៣២,៥លានដុល្លារ (ស្មើនឹងសាំង ៣៤.៧៥៥តោន និងម៉ាស៊ូត ១១៥.៨២០តោន ធៀបនឹងកំរិត ៣៤.៤៥៦តោន និង ៧៦.៦៤៥តោន នៅត្រីមាសទី៤ ២០០៥) ។ ការនាំចូលសំភារៈសំណង់ កើន ៤១% ដល់ ៣៧,០លានដុល្លារ ធៀបនឹង ២៦,២លានដុល្លារ នៅត្រីមាសមុន ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ២០០៦ ឱនភាពថវិកាជាទូទៅរបស់រដ្ឋ មានសភាពកាន់តែធ្ងន់ធ្ងរ ។ តាមទិន្នន័យបានកែតំរូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱនភាពថវិកាទូទៅ កើនដល់ ២៥៩,៨ពាន់លានរៀល ធៀបនឹង ១៧១,០ពាន់លានរៀលនៅត្រីមាសមុន និង ១៥៤,៧ពាន់លានរៀល នៅត្រីមាសដូចគ្នាឆ្នាំ២០០៥ ។ ចំណាយថវិកា និងចំណូលថវិការដ្ឋ បានថយចុះដូចគ្នា ប៉ុន្តែការថយចុះចំណាយ វាមិនធំគ្រប់គ្រាន់អាចជួយកែលំអដល់តុល្យភាពថវិការដ្ឋបានទេ ។ ចាប់តាំងពីត្រីមាសទី២ ២០០៥ ចំណូល និងចំណាយថវិការដ្ឋបានកើនឡើង ប៉ុន្តែវាធ្លាក់ចុះវិញនៅត្រីមាសនេះ ។

ការធ្លាក់ចុះការនាំចូល-នាំចេញ នាំឱ្យការប្រមូលពន្ធនាំចូលនាំចេញធ្លាក់ចុះដែរ ។ ចំណូលសរុប ដែលមានចំណូលពន្ធ ចំណូលមិនមែនពន្ធ និងចំណូលមូលធន ធ្លាក់ចុះអស់ ២៨% មកត្រឹម ៥៩៥,៩ពាន់លានរៀល ធៀបនឹង ៨២៧,៨ពាន់លានរៀល នៅត្រីមាសមុន ។ ចំណូលពន្ធធ្លាក់ចុះអស់ ១៣% មកត្រឹម ៤៨៤,៧ពាន់លានរៀល ដែលនាំមុនគេដោយការធ្លាក់ចុះអាករលើតំលៃបន្ថែម (VAT) អាករពិសេស និងពន្ធគយ ។ ម្យ៉ាងទៀត ចំណូលខាងប្រៃសណីយ៍ និងទូរគមនាគមន៍ ធ្លាក់ចុះអស់ ៧០% ពី ៣៨,០ពាន់លានរៀល មកត្រឹម ១១,៤ពាន់លានរៀល ហើយចំណូលពីអាកាសចរណ៍ស៊ីវិល ធ្លាក់ចុះអស់ ៩៥% មកត្រឹម ០,៤ពាន់លានរៀល ។ ចំណូលមូលធនក្នុងស្រុក ដែលបានពីការធ្វើឯកជនភាវូបនីយកម្ម និងប្រភពផ្សេងទៀត បានធ្លាក់ចុះយ៉ាងខ្លាំង មកត្រឹម ២,៧ពាន់លានរៀល ធៀបនឹង ១២៦,៣ពាន់លានរៀល នៅត្រីមាសមុន ។ ពីខែមករា ដល់ មីនា ២០០៦ ចំណូលថវិកាសរុប សំរេចបាន ២១% នៃផែនការក្នុងច្បាប់ថវិកាឆ្នាំ២០០៦ (២៨១២,៧ពាន់លានរៀល) ធៀបនឹងកំរិត ២៤% ក្នុងកំឡុងពេលដូចគ្នាឆ្នាំ២០០៥ (២២៩៨,៦ពាន់លានរៀល) ។ ចំណូលសរុប ឆ្នាំ២០០៥ (រយៈ ១២ខែ) សំរេចបាន ១១៤% នៃផែនការ (២៦២៥,៣ពាន់លានរៀល) ។ ចំនួលនេះចាំបាច់បំផុតសំរាប់សងបំណុលរដ្ឋ និងសំរាប់ដោះស្រាយចំណាយសាធារណៈ ។ ក្នុងករណីនេះ ចំណូលបានថយចុះ និងបានកាត់បន្ថយសមត្ថភាពសងបំណុល នឹងដោះស្រាយថវិកាសំរាប់ចំណាយសាធារណៈ ។

ក្នុងរយៈពេលនេះដែរ ចំណាយខាងអប់រំ និងសុខាភិបាល បានថយចុះ រីឯចំនាយខាងការពារជាតិ និងសន្តិសុខ កើនឡើងបន្តិច ។ នៅត្រីមាសទី១ ២០០៦ ចំណាយរបស់រដ្ឋ រួមទាំងការកែតំរូវចំណាយផង មានកំរិត ១៤% តិចជាងត្រីមាសមុន ដែលមានដល់ ៨៥៥,៦ពាន់លានរៀល ។ ចំណាយចរន្តគិតលើមូលដ្ឋានសាច់ប្រាក់ ធ្លាក់ចុះ ៩,២% មកត្រឹម ៥៨៨,៨ពាន់លានរៀល ហើយចំណាយមូលធន ធ្លាក់ចុះអស់ ២៤% ។ ចំណាយខាងអប់រំ និងសុខាភិបាល ធ្លាក់ចុះយ៉ាងខ្លាំងអស់ ៦៥% រីឯចំណាយខាងការពារជាតិ និងសន្តិសុខ កើន ៩,៤% ធៀបនឹងត្រីមាសមុន ។ ចំណាយចរន្តខាងសេវាកម្មសាធារណៈផ្សេងទៀត ក៏កើនឡើងដែរ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ចំណាយថវិកាសរុបកើន ២១% ពីកំរិត ៧០៦,៣ពាន់លានរៀល ។ ការថយចុះហិរញ្ញប្បទានបរទេស (ចុះ ៣២%) បានធ្វើឱ្យធ្លាក់ចុះចំណាយមូលធន ។

## អតិផរណា និងអត្រាប្តូរប្រាក់

តាមទិន្នន័យប្រចាំខែចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅនៅភ្នំពេញ នៅត្រីមាសទី១ ២០០៦ កើន ៦,១% ធៀបនឹងមួយឆ្នាំមុន ។ នៅត្រីមាសមុន អត្រាកំណើនប្រចាំឆ្នាំគឺ ៦,៦% ។ ធៀបនឹងត្រីមាសទី៤ ២០០៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់ប្រភេទ ធ្លាក់ចុះ ០,២% ក្នុងនេះ ថ្លៃម្ហូបអាហារធ្លាក់ចុះ ១,០% រីឯថ្លៃទំនិញប្រើប្រាស់ចំបងផ្សេងទៀត ដូចជា ការដឹកជញ្ជូននិងទូរគមនាគមន៍ ការថែទាំសុខភាព ផលិតផលថែទាំកាយ ការអប់រំ លំហែកំសាន្ត សំភារៈប្រើប្រាស់ក្នុងផ្ទះ សំលៀកបំពាក់ និងស្បែកជើង កើនតិចតួច ។ ថ្លៃម្ហូបអាហារ កើន ១១% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៥ ដែលស្មើនឹងកំណើននៅត្រីមាសមុន និងខ្ពស់ជាងកំណើន ៧,៩% នៅត្រីមាសទី១ ឆ្នាំមុន ។ ថ្លៃដឹកជញ្ជូន កើន ៩,៧% ធៀបនឹងឆ្នាំ ២០០៥ រីតិចជាងកំណើន ១០% នៅត្រីមាសមុន ។ ក្នុងត្រីមាសនេះ ការឡើងថ្លៃទំនិញប្រើប្រាស់សំខាន់ៗ ធ្វើឱ្យអ្នកក្រ មានជីវភាពកាន់តែលំបាកថែមទៀត ។ ដូច្នេះកំនើនអតិផរណា វាប៉ះពាល់ជាពិសេសដល់ជីវភាពអ្នកក្រ និងអ្នកមានចំនួលទាប ។

ប្រាក់រៀល ប្តូរបាន ៤០៩៤,៨រៀល/ដុល្លារ រឺឡើងថ្លៃ ១,៥% ធៀបនឹងត្រីមាសមុន ។ ប្រាក់រៀលឡើងថ្លៃ ២,៧% ទល់នឹងប្រាក់ដុងវៀតណាមដោយប្តូរ ២៥,៤រៀល/១០០ដុង ប៉ុន្តែធ្លាក់ថ្លៃទល់នឹងប្រាក់បាតថៃ ដោយប្តូរ ១០៣,៥រៀល/បាត ធៀបនឹង ១០១,៤រៀល/បាតនៅត្រីមាសមុន ។

## ការវិវត្តន៍រូបិយវត្ថុ

តាមអង្កេតហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា រូបិយវត្ថុទូទៅ (M2) នៅចុងត្រីមាសទី១ ២០០៦ កើនបាន ១៤% ដល់ ៥៧១១,០ពាន់លានរៀល (១៣៩២,៩លានដុល្លារUS) ធៀបនឹងត្រីមាសមុន ។ រឿងនេះ បណ្តាលមកពីកំណើនបញ្ញើជារូបិយវត្ថុបរទេស ១៦% ដល់ ៤១៤៦,០ពាន់លានរៀល (១០១១,០លានដុល្លារ) និងកំណើនប្រាក់រៀលក្រៅធនាគារ ៩,៥% ឡើងដល់ ១៤០៣,៥ពាន់លានរៀល (៣៤២,៣លានដុល្លារ) ។ ព្រមជាមួយគ្នា ប្រាក់រៀលក្នុងធនាគារ ដែលរួមមានប្រាក់បញ្ញើចរន្ត ប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើសន្សំ កើន ៥,១% ដល់ ១៦១,០ពាន់លានរៀល (៣៩,៣លានដុល្លារ) ។

រូបិយវត្ថុទូទៅ កើនបាន ៧២% ពីកំរិត ៣៣២៩,០ពាន់លានរៀល (៨១២,០លានដុល្លារ) នៅកំឡុងពេល ១២ខែ ។ សមាសភាគប្រាក់រៀលកើន ៥៤% ក្នុងនេះ ប្រាក់រៀលក្រៅធនាគារកើនបាន ៥៥% ។ នៅពេលជាមួយគ្នា បញ្ញើជារូបិយវត្ថុបរទេស កើន ៨០% ។ គ្រោះថ្នាក់នៃការផ្គត់ផ្គង់រូបិយវត្ថុច្រើនគឺ កំណើនអតិផរណា ពីព្រោះមានលុយច្រើនពេកសំរាប់ដោះស្រាយតំរូវការទំនិញនៅលើទីផ្សារ ។ ម្យ៉ាងទៀត កំណើនបញ្ញើជារូបិយវត្ថុបរទេស បង្ហាញពីទំនុកចិត្តកាន់តែខ្ពស់ទៅលើវិស័យធនាគារ និងគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ការប្រាក់លើកំចីជាដុល្លារ នៅថេរក្នុងពេលកន្លងមក ។ បច្ចុប្បន្ន វាមាន

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

កំរិត ១៦,៤%/ឆ្នាំ ធៀបនឹង ១៦,៧%/ឆ្នាំ នៅឆ្នាំ២០០៤ ។ អត្រាការប្រាក់សំរាប់បញ្ញើជាដុល្លារ ក៏មានស្ថិរភាពដែរ ប្រហែល ៣,៩% ។ នៅត្រីមាសនេះឥណទានសំរាប់វិស័យឯកជនកើន ១៦% ដល់ ២៧៧៨,០ពាន់លានរៀល រីឯឥណទេយ្យសុទ្ធលើរដ្ឋាភិបាល ធ្លាក់ចុះដល់ ៤៥៦,០ពាន់លានរៀល រឺថយចុះ ៤៩% ធៀបនឹងត្រីមាសទី៤ ២០០៥ ដោយសារកំណើនបញ្ញើរបស់រដ្ឋាភិបាល ក្នុងធនាគារ ។ ពិតណាស់ កំណើនឥណទានសំរាប់វិស័យឯកជនវាផុសចេញពីកំណើនសេដ្ឋកិច្ចរឹងប៉ឹង និងបរិយាកាសអត្រាការប្រាស់មានស្ថិរភាព ។ អប្បហារការប្រាក់របស់ធនាគារ (គឺ ផលដករវាងអត្រាការប្រាក់លើប្រាក់ឱ្យខ្ចី និងប្រាក់បញ្ញើ) នៅខ្ពស់នៅឡើយ ដល់ទៅ ១២,៥% ។ អប្បហារ ចុះទាបជាងនេះ នឹងជំរុញឱ្យមានការផ្តល់កំចីកាន់តែច្រើន ហើយវិស័យឯកជន នឹងមានសកម្មភាពសេដ្ឋកិច្ចកាន់តែខ្លាំង ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

យោងតាមអង្កេតលើពលករងាយរងគ្រោះ ១០ក្រុម ធ្វើឡើងដោយ វិបសអ នៅខែឧសភា ចំណូលប្រចាំថ្ងៃពិតជាមធ្យម ធ្លាក់ចុះអស់ ៩,៦% ធៀបនឹងពេលដូចគ្នាឆ្នាំ២០០៥ ។ ចំណូលរបស់អ្នកលក់បន្លែតូចតាច អ្នករើសសំរាម អ្នកបំរើតាមភោជនីយដ្ឋាន អ្នករត់ម៉ូតូឌុប កម្មករគ្មានជំនាញ និងកម្មករសំណង់មានជំនាញ បានធ្លាក់ចុះ រីឯចំណូលរបស់ ៤ ក្រុមផ្សេងទៀត មានអ្នកធាក់ស៊ីក្លូ អ្នកលីសែង កម្មករធ្វើស្រែ និងកម្មករកាត់ដេរ បានកើនឡើង ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ២៣,១% មកត្រឹម ៨.៨០០រៀល ធៀបនឹង ១១.៤០០រៀល នៅខែឧសភា ២០០៥ ប៉ុន្តែ វាមានលក្ខណៈស្រដៀងគ្នានឹងអង្កេតនៅខែកុម្ភៈ ឆ្នាំនេះ ។ ក្នុងអង្កេតនេះ អ្នករត់ម៉ូតូឌុប ៦៨% បានរាយការណ៍ពីការធ្លាក់ចុះចំណូល ១៨% រាយការណ៍ថា គ្មានការប្រែប្រួល និង ១៥% ថាចំណូលកើនឡើង ។ អង្កេតនេះបង្ហាញពីផលប៉ះពាល់នៃការ ឡើងថ្លៃសាំងដល់ ៤.១០០រៀល/លីត្រ នៅខែឧសភា រឺកំណើន ១៩% ធៀបនឹងពេលដូចគ្នាឆ្នាំមុន ។ អ្នករត់ម៉ូតូឌុប ចំណាយពេលប្រហែល ២៤ថ្ងៃ/ខែ និងប្រហែល ១០ម៉ោង/ថ្ងៃ ក្នុងការរត់ម៉ូតូ ហើយពួកគេចំណាយប្រាក់ជាមធ្យម ៤.២០០រៀល/ថ្ងៃលើម្ហូបអាហារ ។ អ្នករត់ម៉ូតូឌុប ៦៣% ត្រូវជួលកន្លែងស្នាក់នៅ ពីព្រោះពួកគេជាជនចំណាកស្រុកមកពីខេត្ត ដើម្បីរកការងារធ្វើនៅភ្នំពេញ ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ២០,២% មកត្រឹម ៩.៨០០រៀល នៅខែឧសភា ឆ្នាំ២០០៦ ធៀបនឹង ១២.៣០០រៀល នៅពេលដូចគ្នាឆ្នាំ២០០៥ ហើយនេះជាតួលេខទាបបំផុតសំរាប់កម្មករសំណង់មានជំនាញ គិតចាប់តាំងពីពេលធ្វើអង្កេតដំបូង នៅឆ្នាំ២០០០ ។ ប៉ុន្តែ មូលហេតុនាំឱ្យចំណូលធ្លាក់ចុះ គេមិនអាចដឹងច្បាស់ទេ ពីព្រោះរបៀបរបបអង្កេតនេះ ធ្វើឱ្យលំបាកក្នុងការរកជួបកម្មករឈ្មោះដដែលដើម្បីសំភាសគាត់ជាថ្មីទៀត ។ ទោះយ៉ាងនេះក្តី កម្មករសំណង់មានជំនាញ ៧៨% បញ្ជាក់ថា ចំនួនកម្មករបានកើនឡើង ។ រឿងនេះមានច្រើន ជាពិសេសចំពោះកម្មករគ្មានជំនាញដែលក្លាយជាមានជំនាញ ក្រោយពីបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយកម្មករសំណង់មានជំនាញមួយពេលយូរមក ។ ក្នុងអង្កេតនេះ ៣៥% នៃកម្មករសំណង់បានសំភាសន៏ ជាអ្នកនៅលីវ ហើយភាគច្រើនមានអាយុតិចជាង ២៥ឆ្នាំ ។ កម្មករមានជំនាញភាគច្រើន ជាជនចំណាកស្រុកបណ្តោះអាសន្នមកពីតំបន់ជនបទ ។

ចំពោះកម្មករគ្មានជំនាញ នៅខែឧសភា ២០០៦ ចំណូលប្រចាំថ្ងៃពិតធ្លាក់ចុះ ២១% ធៀបនឹងនៅកំឡុងពេលដូចគ្នាឆ្នាំ២០០៥ ប៉ុន្តែកើន ៧% ធៀបនឹងអង្កេតលើកមុន នៅខែកុម្ភៈ ។ កម្មករគ្មានជំនាញភាគច្រើន តូញត្អែរថា ចំណូលរបស់ពួកគេគ្មានស្ថិរភាព ដូច្នេះពួកគេមិនអាចសន្សំប្រាក់បានច្រើនសំរាប់ផ្ញើទៅផ្ទះទេ ។ ជាទូទៅ ពួកគេធ្វើការបានប្រហែល ១៥ថ្ងៃ នៅខែឧសភា ២០០៦ និងប្រហែល ៧ម៉ោង/ថ្ងៃ ។ ប្រហែល ៥០% នៃកម្មករគ្មានជំនាញ មានអាយុតិចជាង ២៥ឆ្នាំ ហើយ ៧៥% ធ្លាប់បានចូលរៀនបឋមសិក្សា ២០% ធ្លាប់បានរៀននៅមធ្យមសិក្សា និង ៥% ទៀត មិនបានរៀនសោះ ។

*កម្មករគ្មានជំនាញភាគច្រើន តូញត្អែរថា ចំណូលរបស់ពួកគេគ្មានស្ថិរភាព ដូច្នេះពួកគេមិនអាចសន្សំប្រាក់បានច្រើនសំរាប់ផ្ញើទៅផ្ទះទេ ។ ជាទូទៅ ពួកគេធ្វើការបាន ប្រហែល ១៥ថ្ងៃ នៅខែឧសភា ឆ្នាំ២០០៦ និងប្រហែល ៧ម៉ោង/ថ្ងៃ ។ ប្រហែល ៥០% នៃកម្មករគ្មានជំនាញ មាន អាយុតិចជាង ២៥ឆ្នាំ ហើយ ៧៥% ធ្លាប់បានចូលរៀនបឋមសិក្សា ២០% ធ្លាប់បានរៀននៅមធ្យមសិក្សា និង ៥% ទៀត មិនបានរៀនសោះ ។*

នៅខែឧសភា ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់បន្លែតូចតាច ធ្លាក់ចុះ ២៤,៣% មកត្រឹម ៦.៥០០រៀល ធៀបនឹង ៨.៦០០រៀល នៅកំឡុងពេលដូចគ្នាឆ្នាំ២០០៥ ។ ចំណូលវាធ្លាក់ចុះដោយសារថ្លៃបន្លែគ្មានស្ថិរភាព និងកំណើនចំនួនអ្នកលក់បន្លែ ។ អ្នកលក់បន្លែបានឆ្លើយសំភាសន៏ ៨២% រាយការណ៏ថា ចំនួនអ្នកលក់បន្លែកើនឡើង ដោយសារអ្នកលក់បន្លែគ្រាច់ចរពីខេត្តកណ្តាល និងកំពង់ស្ពឺ ដែលមករកស៊ីនៅភ្នំពេញ ពីព្រោះមានលក្ខខណ្ឌមិនអំណោយផលនៅភូមិស្រុករបស់ពួកគេ ។ អ្នកលក់បន្លែភាគច្រើន ត្រូវចំណាយពេលយ៉ាងច្រើននៅឯទីផ្សារ រួមទាំងការក្រោកពីដំណេកនៅម៉ោង៣ព្រឹក ដើម្បីទៅទិញបន្លែសំរាប់លក់ផង ។ អ្នកលក់តូចតាច ប្រមាណ ៨៥% និយាយថា ក្នុងកំរិតចំណូលនេះ ពួកគេមិនអាចសន្សំអ្វីសំរាប់ពង្រីកការរកស៊ីបានទេ ។ អង្កេត ក៏បង្ហាញដែរថា មានក្មេងស្រីជាច្រើន អាយុពី ១០ ទៅ ១៥ឆ្នាំ ទូលកញ្ច្រែង ផ្លែឈើ និងបន្លែ ដើរលក់ ។ តាមសំភាសន៏មិនផ្លូវការជាមួយក្មេងស្រីទាំងនេះ បានរកឃើញថា ពួកគេរកបានពី ១.៥០០រៀល ទៅ ២.០០០រៀលក្នុងមួយថ្ងៃ ប៉ុន្តែ អ្នកខ្លះត្រូវចំណាយពេលកន្លះថ្ងៃ និងខ្លះទៀតពេញមួយថ្ងៃ ដើម្បីជួយការងារក្នុងគ្រួសារ ។ ក្មេងស្រីលក់បន្លែខ្លះនិយាយថា ជាទូទៅ ពួកគេធ្វើការរកស៊ី ក្រោយពេលចប់ម៉ោងនៅសាលារៀន ប៉ុន្តែ ខ្លះទៀតត្រូវធ្វើដំណើរចេញពីភូមិកំណើតជាមួយគ្រួសារតាំងពីព្រលឹមរាល់ថ្ងៃ ដូច្នេះហើយត្រូវតែឈប់រៀន ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសសំរាម នៅខែឧសភា ធ្លាក់ចុះ ១៤,៤% មកត្រឹម ៤.៥០០រៀល ធៀបនឹង ៥.៣០០រៀល នៅខែដូចគ្នា ឆ្នាំ២០០៥ ។ តាំងពីដើមឆ្នាំ២០០៦ ចំណូលប្រចាំថ្ងៃរបស់អ្នករើសសំរាម បន្តធ្លាក់ចុះរហូត ហើយនៅខែឧសភា អ្នកឆ្លើយសំភាសន៏ ៩២% លើកឡើងថា ចំណូលរបស់ពួកគេបានធ្លាក់ចុះ និង ៨% ផ្សេងទៀតលើកថា នៅថេរដដែល ។ តាមយោបល់អ្នកឆ្លើយសំភាសន៏ ការធ្លាក់ចុះចំណូលនេះ បណ្តាលពីការចុះថ្លៃរបស់អេតចាយ ធៀបនឹងរយៈពេល ៣ខែចុងក្រោយ ។ អ្នករើសអេតចាយ

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

៦៥% ដែលបានឆ្លើយសំភាសន៍ គឺជាជនចំណាកស្រុកមកពីជនបទ ហើយ ៣៥% ទៀតច្រើនជាអ្នករស់នៅក្បែរកន្លែងចាក់សំរាមតែម្តង ។ ជនចំណាកស្រុកភាគច្រើន មកជាមួយគ្រួសាររបស់ពួកគេ ហើយមួយភាគធំ ជួលផ្ទះស្នាក់នៅក្នុងភូមិក្បែរកន្លែងចាក់សំរាម ។ គេបានរាយការណ៍ថា ជនចំណាកស្រុកចំនួន ៥៨% គ្មានដីធ្លីទេ ហើយ ៣១% មានដីតិចជាង ១ ហិកតា ។ អ្នករើសអេតចាយដែលឆ្លើយសំភាសន៍ បានត្អូញត្អែរថា ចំណូលប្រចាំថ្ងៃរបស់ពួកគេ គ្មានស្ថិរភាពទេ ហើយពួកគេរកបានសំរាប់តែមួយរស់ប៉ុណ្ណោះ ។

នៅខែឧសភា ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ គឺ ៧.៨៦០រៀល រីកើន ៨,៦% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៥ ប៉ុន្តែធ្លាក់ចុះ ១៤,៤% ធៀបនឹងអង្កេតលើកមុន នៅខែកុម្ភៈ ។ កម្មករកាត់ដេរ នៅខែឧសភា ចំណាយអស់ជាមធ្យម ៣៦ដុល្លារ បូកទាំងម្ហូបអាហារផង ។ មានកម្មករតែ ១៧,៥% ប៉ុណ្ណោះដែលនិយាយថា អាចសន្សំប្រាក់បានខ្លះក្នុងចំណូលនេះ ។ កម្មករប្រហែល ៦០% បានផ្ញើប្រាក់ទៅឱ្យក្រុមគ្រួសាររបស់ខ្លួន ។ អង្កេតបង្ហាញថា កម្មករកាត់ដេរ ៧៥% គ្មានជំនាញទេ មុនពេលពួកគេទៅធ្វើការក្នុងរោងចក្រ ២១% និយាយថា បានទទួលការបណ្តុះបណ្តាលពីក្រុមហ៊ុនបណ្តុះបណ្តាលឯកជន និង ៤% ទៀតប្រាប់ថា បានទទួលការបណ្តុះបណ្តាលនៅផ្ទះ ។ យោងតាមលទ្ធផលអង្កេត កម្មករកាត់ដេរ ១០% ជាកម្មករអណ្តែត និង ៩០% ជាកម្មករពេញសិទ្ធិ ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នកធាក់ស៊ីក្លូ និងអ្នកលីសែង កើន ១០,៦% និង ៤,៥% នៅខែឧសភា ឆ្នាំ២០០៦ ធៀបនឹងអង្កេតដូចគ្នា ឆ្នាំ ២០០៥ ។ ប៉ុន្តែ ចំនួនពាក់កណ្តាលនៃអ្នកធាក់ស៊ីក្លូ និងអ្នកលីសែង ប្រាប់ថា ចំណូលរបស់ពួកគេ អាចដោះស្រាយបានតែមួយចំណែកតូចនៃតំរូវការក្នុងការទ្រទ្រង់ជីវភាពគ្រួសារប៉ុណ្ណោះ ។ ជាទូទៅ អ្នកធាក់ស៊ីក្លូចំណាយ ៤.៤០០រៀល/ថ្ងៃ ហើយអ្នកលីសែងចំណាយ ៣.៧០០រៀល/ថ្ងៃ លើម្ហូបអាហារ គឺច្រើនជាងឆ្នាំមុន ១៦% និង ៩% ។ ទាំងអ្នកធាក់ស៊ីក្លូ នឹងអ្នកលីសែង ជាជនចំណាកស្រុកពីតំបន់ជនបទ ហើយពួកគេធ្វើការ ២៥ថ្ងៃក្នុងខែឧសភា និងប្រហែល ៧ខែក្នុងមួយឆ្នាំ ។

**កំណត់សំគាល់**

១. ប្រភព: គណនាចេញពីទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ

*រៀបរៀងដោយ ប៊ុន ដូរីណា និងផាន់ ដាលីស*


## Cambodia Development Review – 2006 Subscription Rates

**Domestic Subscription (Individual)**

❑ English edition ($14) ❑ Khmer edition (5,000r) Payment by ❑ cash ❑ cheque ❑ Telegraphic Transfer

Total payment enclosed ____________

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❑ English edition ($60 for five copies) ❑ Khmer edition (20,000r for five copies)

Payment by ❑ cash ❑ cheque ❑ Telegraphic Transfer. Total payment enclosed ____________

**International Subscription (Individual)**

❑ Thailand, Laos, Vietnam ❑ English edition ($25)* ❑ Khmer edition ($15)*

❑ Asia and Europe ❑ English edition ($30)* ❑ Khmer edition ($20)*

❑ Americas and Africa ❑ English edition ($35)* ❑ Khmer edition ($25)*

At present CDRI can accept payment from overseas only by US-dollar dominated cheque or By Telegraphic Transfer.

Total payment enclosed ____________

**Payment options:**

1. By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
   Transfer to:
   Account Name: CDRI
   Account Number: 133451
   Bank Name: ANZ Royal Bank
   Bank Address: Phnom Penh, Cambodia
   Swift Code: ANZBKHPP
   Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
   Swift Code: CHASUS33
   CHIP UID 004966

2. By Cheque - Please add (overseas) $50 (local) $2 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications at the address shown at the masthead.

Title: ❑ Mr ❑ Ms ❑ Dr ❑ Other: ________ First name: ____________ Last name: ____________

Position: ____________ Organisation / Company: ____________

Address (CCC Box if applicable): ____________

City / Province: ____________ Country: ____________

Telephone: ____________ Fax: ____________

e-mail: ____________ ❑ Tick this box to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Please make cheques payable to the Cambodia Development Resource Institute. Do not send cash through the post.
Please inform the Publications Section at CDRI if your contact details change.

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000* | 2001* | 2002* | 2003* | 2004* | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 51.6 | 63.9 | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 3.2 | 4.0 | 10.4 | 9.1 | 126.5 |
| ឧស្សាហកម្ម | 650.5 | 162.6 | 109.4 | 105.2 | 67.7 | 137.2 | 189.2 | 418.8 | 62.1 | 349.7 | 82.0 | 40.1 |
| *កាត់ដេរ* | *126.5* | *67.7* | *81.5* | *26.5* | *27.2* | *68.1* | *133.9* | *44.9* | *23.2* | *56.5* | *27.3* | *30.5* |
| សេវាកម្ម | 154.7 | 222.6 | 150.1 | 118.4 | 145.3 | 168.4 | 92.0 | 53.3 | 30.0 | 44.1 | 28.1 | 60.7 |
| *សណ្ឋាគារ និងទេសចរណ៍* | *112.0* | *171.8* | *79.8* | *73.8* | *47.1* | *124.1* | *55.9* | *46.4* | *0.0* | *33.6* | *22.6* | *0.0* |
| សរុប | 856.8 | 449.1 | 269.2 | 224.0 | 253.3 | 309.3 | 293.5 | 475.3 | 96.1 | 404.2 | 119.2 | 227.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 2798.2 | -79.8 | 320.6 | -70.5 | 90.7 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -12.4 | 650.8 | -15.2 | 392.9 | 628.1 | -52.2 |

** revised and including expansion project approvals. Source: Cambodian Investment Board.*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 14.3 | 6.6 | 19.2 | 5.4 | 10.1 |
| ផ្ទះល្វែង | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 48.6 | 69.1 | 41.3 | 45.1 | 39.9 |
| ផ្សេងៗ | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 43.1 | 28.6 | 16.0 | 21.3 | 17.4 |
| សរុប | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 263.4 | 106.1 | 104.4 | 76.5 | 71.8 | 67.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 65.5 | -1.6 | -26.7 | -6.1 | -6.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 32.5 | 45.5 | 114.8 | -1.8 | 12.0 | -36.5 |

*Source: Department of Cadastre and Geography of the Municipality of Phnom Penh*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 784.4 | 941.1 | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 463.0 | 515.0 | 730.0 | 644.8 | 603.2 |
| រួមមានៈ សំលៀកបំពាក់ | 378.0 | 554.0 | 962.1 | 1202.2 | 1355.8 | 1628.4 | 2027.0 | 444.9 | 497.6 | 709.8 | 601.0 | 568.5 |
| - ទៅសហរដ្ឋអាមេរិក | 74.1 | 486.0 | 714.1 | 840.9 | 943.4 | 1099.8 | 1270.9 | 312.5 | 335.9 | 489.5 | 408.1 | 402.5 |
| - ទៅសហគមន៏អឺរ៉ុប | - | - | 228.1 | 323.3 | 356.3 | 414.7 | 590.8 | 89.2 | 106.0 | 162.5 | 145.3 | 110.6 |
| - ប្រទេសផ្សេងទៀត | 82.0 | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 165.3 | 43.1 | 55.7 | 57.8 | 47.5 | 55.3 |
| កសិកម្ម | - | - | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 18.1 | 17.3 | 20.2 | 43.8 | 34.7 |
| - កៅស៊ូ | - | - | 29.6 | 25.9 | 29.7 | 35.1 | 38.3 | 7.3 | 6.2 | 9.8 | 13.4 | 7.8 |
| - ឈើ | - | - | 32.9 | 22.3 | 16.0 | 10.2 | 11.1 | 3.3 | 2.9 | 2.1 | 2.0 | 2.1 |
| - ត្រី | - | - | 5.4 | 6.0 | 4.3 | 2.8 | 10.6 | 1.5 | 1.1 | 0.8 | 6.6 | 1.9 |
| - ផ្សេងៗ | - | - | 26.2 | 11.8 | 47.4 | 31.6 | 21.3 | 6.0 | 7.1 | 7.5 | 21.9 | 22.9 |
| ការនាំចូលសរុប | 1112.2 | 1237.4 | 1417.7 | 1501.4 | 1707.8* | 1824.9 | 2149.0 | 520.7 | 666.4 | 632.3 | 691.1 | 690.7 |
| រួមមានៈ - សាំង | - | - | - | - | 25.9 | 33.2 | 30.2 | 10.3 | 9.3 | 9.9 | 10.7 | 10.9 |
| - ម៉ាស៊ូត | - | - | - | - | 100.8 | 109.6 | 109.4 | 21.6 | 25.8 | 24.6 | 21.1 | 32.5 |
| - សំភារៈសំណង់ | - | - | - | - | 12.9 | 80.8 | 95.3 | 32.3 | 37.1 | 38.7 | 26.2 | 37.0 |
| - ផ្សេងៗ | - | - | - | - | 1568.2 | 1601.3 | 1914.0 | 456.5 | 594.2 | 559.1 | 633.1 | 610.3 |
| ជញ្ជីងពាណិជ្ជកម្ម | -327.8 | -296.3 | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -57.7 | -151.4 | 97.7 | -46.3 | -87.5 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | -14.5 | 11.8 | 42.6 | -15.3 | -5.4 |
| ការនាំចេញសរុប | - | - | - | - | - | - | - | -15.1 | 11.2 | 41.7 | -11.7 | -6.4 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -5.0 | 28.0 | -5.1 | 9.3 | -0.03 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 16.0 | 3.8 | 10.3 | 15.5 | 27.8 |
| ការនាំចេញសរុប | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 15.9 | 4.1 | 9.2 | 18.3 | 30.3 |
| ការនាំចូលសរុប | 1.6 | 11.3 | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 13.7 | 9.9 | 20.5 | 26.1 | 32.6 |

*Imports include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អ្នកដំណើរពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 231.7 | 169.8 | 202.8 | 251.5 | 275.4 |
| តាមផ្លូវគោក និងទឹក | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 148.9 | 124.0 | 120.4 | 164.5 | 181.9 |
| សរុប | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 380.6 | 293.8 | 323.2 | 416.0 | 457.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 0.5 | -22.8 | 10.0 | 28.7 | 9.9 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 49.6 | 51.6 | 41.8 | 9.8 | 20.2 |

*ប្រភពៈ ក្រសួងទេសចរណ៍ ។*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៨-២០០៦ (ពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 920 | 1326 | 1528 | 1529 | 1744 | 1765 | 2127 | 551.6 | 621.9 | 624.0 | 827.8 | 595.9 |
| ចំណូលចរន្ត | - | - | - | 1521 | 1728 | 1733 | 2107 | 551.3 | 611.5 | 609.5 | 701.6 | 593.2 |
| ចំណូលពន្ធ | 676 | 956 | 1096 | 1096 | 1227 | 1220 | 1577 | 455.1 | 466.0 | 436.2 | 553.8 | 484.7 |
| ពន្ធគយ | 376 | 432 | 376 | 376 | 424 | 395 | 513 | 129.4 | 129.7 | 123.7 | 189.8 | 135.5 |
| ចំណូលមិនមែនពន្ធ | 204 | 348 | 424 | 424 | 501 | 513 | 530 | 96.2 | 145.5 | 173.2 | 147.8 | 108.5 |
| អាជីវកម្មព្រៃឈើ | 20 | 36 | 28 | 29 | 15 | 7 | 2 | 1.3 | 1.5 | 0.3 | 0.1 | 0.5 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 88 | 108 | 124 | 122 | 123 | 120 | 94 | 21.9 | 32.0 | 30.9 | 38.0 | 11.4 |
| ចំណូលជាមូលធន | 36 | 12 | 8 | 9 | 16 | 31 | 19 | 0.3 | 10.4 | 14.6 | 126.3 | 2.7 |
| ចំណាយសរុប | 1296 | 1792 | 2332 | 2332 | 2948 | 2757 | 2932 | 706.3 | 713.7 | 912.9 | 998.9 | 855.6 |
| ចំណាយជាមូលធន | 368 | 624 | 976 | 977 | 1388 | 1171 | 1163 | 326.3 | 315.9 | 335.4 | 350.3 | 266.9 |
| ចំណាយចរន្ត | 980 | 1164 | 1356 | 1355 | 1560 | 1586 | 1769 | 380.0 | 397.8 | 577.0 | 648.6 | 588.8 |
| អប់រំ និងសុខាភិបាល | 132 | 280 | 344 | 343 | 454 | 473 | 518 | 52.5 | 92.3 | 202.1 | 228.4 | 80.3 |
| ការពារជាតិ និងសន្តិសុខ | 448 | 464 | 404 | 405 | 438 | 411 | 423 | 74.9 | 73.9 | 116.7 | 71.4 | 78.1 |
| ក្រសួងផ្សេងៗទៀត | 332 | 412 | 636 | 637 | 668 | 702 | 828 | 252.6 | 231.7 | 258.2 | 348.8 | 430.4 |
| ឱនភាពជាទូទៅ | -380 | -476 | -804 | -803 | -1204 | -992 | -805 | -154.7 | -91.9 | -288.3 | -171.0 | -259.8 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 268 | 416 | 768 | 766 | 1249 | 886 | 864 | 266.7 | 255.7 | 335.8 | 269.0 | 184.0 |
| ហិរញ្ញប្បទានក្នុងស្រុក | 112 | 60 | 36 | 37 | -45 | 106 | 148 | -111.9 | -163.9 | -47.5 | -97.9 | 75.8 |

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001* | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ខេត្ត | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 20.7 | 21.5 | 14.5 | 16.6 | 15.8 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 14.8 | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 5.6 | 6.4 | 4.6 | 6.6 | 6.1 |
| - ម្ហូបអាហារ | 14.1 | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 7.9 | 9.8 | 6.0 | 10.6 | 10.6 |
| - ដឹកជញ្ជូន | 15.1 | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 12.3 | 11.1 | 11.9 | 10.2 | 9.7 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | - | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4027.0 | 4054.3 | 4134.3 | 4154.3 | 4094.8 |
| រៀលក្នុង ១ បាតថៃ* | - | - | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 104.4 | 101.3 | 100.2 | 101.4 | 103.5 |
| រៀលក្នុង ១០០ ដុងវៀតណាម* | - | - | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.1 | 25.3 | 25.9 | 26.1 | 25.4 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 40.4 | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 52.6 | 52.5 | 55.4 | 57.0 | 64.2 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 883 | 1065 | 1105 | 1329 | 1521 | 1508 | 3442 | 2350 | 2500 | 2767 | 2921 | 2867 |
| ថ្លៃសាំង (រៀល/លីត្រ) | 1378 | 1613 | 1760 | 2113 | 2084 | 2150 | 2633 | 3050 | 3300 | 3633 | 3750 | 3767 |

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៨-២០០៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1726 | 2019 | 2589 | 3080 | 3737 | 4027 | 4797 | 4883 | 5084 | 5391 | 5475 | 6410 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -496 | -576 | -759 | -876 | -849 | -698 | -467 | -385 | -455 | -397 | -450 | -699 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 178 | 103 | 3 | -75 | -119 | -128 | -209 | -252 | -343 | -404 | -421 | -755 |
| ឥណទានចំពោះផ្នែកឯកជន | 655 | 763 | 898 | 936 | 1059 | 1337 | 1817 | 1983 | 2166 | 2386 | 2394 | 2778 |
| រូបិយវត្ថុទូទៅ M2 | 1230 | 1443 | 1831 | 2204 | 2888 | 3328 | 4329 | 4498 | 4629 | 4994 | 5025 | 5711 |
| រូបិយវត្ថុ M1 | 543 | 531 | 540 | 609 | 813 | 937 | 1153 | 1198 | 1215 | 1279 | 1323 | 1449 |
| រូបិយវត្ថុផ្សេងៗ | 687 | 911 | 1291 | 1594 | 2075 | 2391 | 3176 | 3300 | 3414 | 3715 | 3702 | 4262 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 30.0 | 22.9 | 20.4 | 19.8 | 16.1 | 27.0 |
| រូបិយវត្ថុ M1 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 19.0 | 16.8 | 18.6 | 14.7 | 20.9 |
| រូបិយវត្ថុផ្សេងៗ | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 32.8 | 20.3 | 21.7 | 20.2 | 16.6 | 33.6 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2002 | 2003 | 2004 | 2005 | | | 2006 | | 2005 | 2006 | |
| | វិច្ឆិកា | | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8975 | 8572 | 7614 | 7726 | 7857 | 7768 | 7873 | 8546 | 4.7 | -7.7 | 10.6 |
| អ្នកលីសែង | 6233 | 7044 | 6676 | 6895 | 7056 | 6000 | 6473 | 6519 | 7375 | -4.0 | -6.0 | 4.5 |
| អ្នកលក់បន្លែតូចតាច | 5256 | 6566 | 6532 | 6947 | 8574 | 5938 | 8385 | 6186 | 6492 | 5.4 | -3.1 | -24.3 |
| អ្នករើសអេតចាយ | 2718 | 3685 | 3944 | 4446 | 5270 | 4335 | 4801 | 4984 | 4512 | 11.3 | -7.4 | -14.4 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4365 | 4932 | 4448 | 4287 | 4648 | 3893 | 4670 | 4243 | -2.8 | 4.5 | -1.0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4304 | 4177 | 4139 | 3822 | 4009 | 4224 | 4127 | 4541 | -3.0 | 3.3 | 18.8 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 8904 | 9577 | 9277 | 7235 | 8756 | 8659 | 9184 | 7860 | -8.7 | -0.3 | 8.6 |
| អ្នករត់ម៉ូតូឌុប | 8,610 | 12,184 | 10,092 | 9204 | 11,130 | 9406 | 9645 | 8884 | 8790 | 14.8 | -24.5 | -23.1 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6453 | 6558 | 6382 | 8130 | 6069 | 6691 | 5974 | 6407 | 4.3 | 3.9 | -21.2 |
| កម្មករសំណង់មានជំនាញ | 13,127 | 12,605 | 13,111 | 12,679 | 12,320 | 10,273 | 11,253 | 11,750 | 9833 | -4.9 | -18.2 | -20.2 |

*សំគាល់: ចំនួនអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ * ចំនួនអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្តល់ឱ្យទេ ។ ប្រភព: តារាង៥: ទិន្នន័យបណ្តោះអាសន្នឆ្នាំ ២០០៤-០៥ និង Q1 ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: * លេខកែតំរូវ CDRI, IMF, NIS, ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៧:NBC / តារាង៨: វបសអ ។*